**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:២២៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការទទួលស្គាល់សហព័ន្ធស្រូវ-អង្ករកម្ពុជា (ស.អ.ក)**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រា១.~** ទទួលស្គាល់ **សហព័ន្ធស្រូវ-អង្ករកម្ពុជា** (សរសេរជាអក្សរកាត់ **ស.អ.ក**) ជាស្ថាប័នឯកជនតែមួយគត់សម្រាប់វិស័យស្រូវអង្ករនៅកម្ពុជា ដែលស្ថិតក្រោមអភិបាលកិច្ចផ្នែកបច្ចេកទេសរបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា២.~** កំណត់ឲ្យ **សហព័ន្ធស្រូវ-អង្ករកម្ពុជា** ធ្វើជាដៃគូរបស់រាជរដ្ឋាភិបាល ចូលរួមរាល់សកម្មភាពរបស់សហគមន៍ស្រូវអង្ករនៃបណ្តាប្រទេសអាស៊ាន ចូលរួមចរចារជាមួយរដ្ឋាភិបាលនៃ

បណ្តាប្រទេសនាំចូលអង្ករ រៀបចំប្រចាំឆ្នាំនូវសន្និសីទតាំងពិព័រណ៍ស្រូវ-អង្ករថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំងចូលរួមក្នុងការងារផលិតពូជស្រូវសម្រាប់ចែកចាយជូនប្រជាកសិករ ។

**មាត្រា៣.~** សហព័ន្ធស្រូវអង្ករកម្ពុជាអាចចាត់តំណាងឲ្យចូលរួមក្នុងបណ្តាក្រុមការងារតាមវិស័យពាក់ព័ន្ធស្ថិតក្រោមគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយរដ្ឋាភិបាល ។

**មាត្រា៤.~** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.~** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ខែសីហាឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជានាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ